

# Multi-Licensing (ការផ្តល់ពហុអាជ្ញាប័ណ្ណ)

## *តើចក្ខុវិស័យរបស់ DCYF គឺជាអ្វី?*

DCYF ចង់នាំយកសេវាកម្មមកដាក់រួមគ្នា ដូច្នេះកុមារ និងយុវជនទាំងអស់ក្នុងទីក្រុង Washington ធំលូតលាស់ដោយសុវត្ថិភាព និងមានសុខភាពល្អ មានភាពរីកចម្រើនផ្លូវកាយ អារម្មណ៍ និងការសិក្សា ហើយត្រូវបានចិញ្ចឹមបីបាច់ដោយគ្រួសារ និងសហគមន៍។

## តើការផ្តល់ពហុអាជ្ញាប័ណ្ណជាអ្វី?

ការផ្តល់ពហុអាជ្ញាប័ណ្ណគឺជាការអនុម័តចំពោះអ្នកទទួលអាជ្ញាប័ណ្ណឱ្យកាន់អាជ្ញាប័ណ្ណសេវាថែទាំក្រៅផ្ទះលើសមួយប័ណ្ណ ពោលគឺអាជ្ញាប័ណ្ណសេវាថែទាំកុមារតាមផ្ទះលក្ខណៈគ្រួសារ និងអាជ្ញាប័ណ្ណសេវាថែទាំកុមារដែលមានអាជ្ញាប័ណ្ណ ឬមានត្រូវបានបញ្ជាក់មួយ ឬច្រើនប័ណ្ណ។

ការផ្តល់ពហុអាជ្ញាប័ណ្ណលុបបំបាត់ឧបសគ្គ ដែលបង្កលក្ខណៈកាន់តែងាយស្រួលសម្រាប់គ្រួសារធ្វើប្រតិបត្តិការទាំងជាអ្នកផ្តល់សេវាថែទាំកូននិងសេវាផ្ញើកូនឲ្យគេចិញ្ចឹមថែទាំ គ្រួសារដែលមានអាជ្ញាប័ណ្ណ DCYF ច្រើនប័ណ្ណអាចផ្តល់សេវាថែទាំ និងការគាំទ្រយ៉ាងរលូនជាបន្តបន្ទាប់ដល់កុមារ និងយុវជន។

## តើវាដំណើរការយ៉ាងដូចម្តេច?

- សូមទាក់ទងតាមប្រអប់សារស្វាគមន៍របស់ DCYF នៅលើគេហទំព័រ **dcyf.welcome@dcyf.wa.gov** ដើម្បីស្រែកព័ត៌មានបន្ថែម និងដំណើរការផ្តល់អាជ្ញាប័ណ្ណ។
- ជំនួយបច្ចេកទេសដំបូង និងជាបន្តបន្ទាប់គឺអាចរកបានពីការបណ្តុះបណ្តាល និងការអនុវត្តមុនពេលបម្រើសេវាតាមរយៈការផ្តល់អាជ្ញាប័ណ្ណ និងការថែទាំ។

## ព័ត៌មានបន្ថែម

- សូមមើលព័ត៌មានបច្ចុប្បន្នភាព Washington Administrative Code (ច្បាប់រដ្ឋបាលវ៉ាស៊ីនតោន, WAC)៖
  - 110-148-1330: **https://app.leg.wa.gov/WAC/default.aspx?cite=110-148-1330**
  - 110-300-0425: **https://app.leg.wa.gov/WAC/default.aspx?cite=110-300-0425**
  - 110-300-0430: **https://app.leg.wa.gov/WAC/default.aspx?cite=110-300-0430**
- អ្នកអាចមានទាំងអាជ្ញាប័ណ្ណសេវាថែទាំសហគមន៍ ឬអាជ្ញាប័ណ្ណសេវាថែទាំគ្រួសារក្នុងពេលតែមួយនឹងអាជ្ញាប័ណ្ណសេវាថែទាំកុមារ។
- គ្រួសារចិញ្ចឹមថែទាំដែលទទួលបានអាជ្ញាប័ណ្ណតាមរយៈ Child Placing Agencies (ភ្នាក់ងារដាក់កុមារ, CPAs) មានជម្រើសដូចគ្នាក្នុងការកាន់អាជ្ញាប័ណ្ណច្រើនប័ណ្ណបា។
- អ្នកទទួលអាជ្ញាប័ណ្ណដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់អាចទទួលបានប្រាក់សំណងថែទាំកុមាប្រចាំខែ និងប្រាក់ឧបត្ថម្ភធនសម្រាប់ការថែទាំកូន ព្រមទាំងប្រាក់ថែទាំសុខភាពកូន។
- ចំនួនកុមារអតិបរមានៅក្នុងមជ្ឈមណ្ឌលចិញ្ចឹមថែទាំមានអាជ្ញាប័ណ្ណគឺប្រាំមួយនាក់នៅក្នុងមជ្ឈមណ្ឌលដែលមានអាជ្ញាប័ណ្ណជាមួយនឹងអ្នកថែទាំពីរនាក់ ឬកុមារបួននាក់នៅក្នុងមជ្ឈមណ្ឌលដែលមានអាជ្ញាប័ណ្ណជាមួយអ្នកថែទាំម្នាក់។ នេះរាប់បញ្ចូលទាំងកូនរបស់អ្នកផ្ទាល់ដែលមានអាយុក្រោម 18 ឆ្នាំ និងកុមារក្នុងការថែទាំចិញ្ចឹម ឬថែទាំបណ្តោះអាសន្ន។
- សមត្ថភាពអតិបរមានៃការថែទាំកុមារអាស្រ័យទៅលើទំហំនៃកន្លែងរបស់អ្នក ចំនួនបុគ្គលិក ការអប់រំ និងការបណ្តុះបណ្តាល និងកត្តាផ្សេងៗទៀត។
- អាជ្ញាប័ណ្ណនីមួយៗគឺដាច់ដោយឡែកពីគ្នា។ អ្នកទទួលបានអាជ្ញាបណ្ណអាចជ្រើសរើសបិទអាជ្ញាប័ណ្ណមួយ ហើយទុកអាជ្ញាប័ណ្ណផ្សេងទៀតបាន។

## ចាប់អារម្មណ៍ដែរទេ? មានសំណួរដែរទេ?

សូមទាក់ទង DCYF តាមគេហទំព័រ **dcyf.welcome@dcyf.wa.gov**

---

*DCYF មិនរើសអើង និងផ្តល់លទ្ធភាពទទួលបានកម្មវិធី និងសេវាកម្មរបស់ខ្លួនស្មើៗគ្នាសម្រាប់មនុស្សទាំងអស់ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ យេនឌ័រ សាសនា ជំនឿ ស្ថានភាពអាពាហ៍ពិពាហ៍ ដើមកំណើតជាតិ សញ្ជាតិ ឬស្ថានភាពអន្តោប្រវេសន៍ អាយុ ទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ អតីតយុទ្ធជន ឬស្ថានភាពយោធា ស្ថានភាពជាម្តាយបំបៅកូនដោយទឹកដោះ និងការមានពិការភាពផ្លូវកាយ ផ្លូវអារម្មណ៍ ឬផ្លូវចិត្ត ឬការប្រើឆ្កែនាំផ្លូវ ឬសត្វបម្រើ។ ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃឯកសារបោះពុម្ពនេះដោយឥតគិតថ្លៃជាទម្រង់ ឬភាសាផ្សេងទៀត សូមទាក់ទងផ្នែកទំនាក់ទំនងមណ្ឌល DCYF តាមរយៈលេខ 1-800-723-4831 ឬអ៊ីមែល* ***communications@dcyf.wa.gov*** *។*

DCYF PUBLICATION LIC_0159 CA (10-2024) Cambodian

Washington State Department of
CHILDREN, YOUTH & FAMILIES